# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :.....០២៩/២១.....**ក.ប**/ខ.ល

## សារលិខិតជូនពរ

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

***សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

នាឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ ក្នុងខួបលើកទី ៣៦ នៃការឡើងកាន់ដំណែងជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជារបស់ **សម្តេចតេជោ** គិតចាប់ពីថ្ងៃ១៤ ខែមករា ឆ្នាំ១៩៨៥ រហូតដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១នេះ យើងខ្ញុំសូមសម្តែងនូវអំណរសាទរដោយស្មោះអស់ពីដួងចិត្ត និងសូមគោរពជូនពរនូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខដ៏មហាប្រសើរគ្រប់ប្រការជូន **សម្តេចតេជោ** សូមបានសមប្រកបដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា និងជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំនាវាកម្ពុជាឆ្ពោះទៅរកសុខសន្តិភាព និងការអភិវឌ្ឍជានិរន្តរ៍តរៀងទៅ។

ឆ្លៀតក្នុងឱកាសដ៏មហាវិសេសវិសាលនេះ យើងខ្ញុំសូមសម្តែងនូវមោទកភាព និងការគោរពកោតសរសើរដ៏ស្មោះបំផុតជូនចំពោះ **សម្តេចតេជោ** ដែលជាឥស្សរជនខ្មែរដ៏ឆ្នើមបំផុតមួយរូប បានលះបង់អស់កម្លាំងកាយចិត្ត ប្រាជ្ញា និងស្មារតី ប្រកបដោយគតិបណ្ឌិត ភាពឈ្លៀសវៃ និងភាពអង់អាច ក្នុងការដឹកនាំរំដោះប្រទេសជាតិចេញផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ឈានដល់ការផ្សះផ្សារ បង្រួបបង្រួមជាតិក្រោមនយោបាយ "ឈ្នះ-ឈ្នះ" ដែលបាននាំមកនូវឯកភាពជាតិ ស្ថិរភាពនយោបាយ សុខសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ ជូនប្រជាជន និងជាតិមាតុភូមិទាំងមូល។

យើងខ្ញុំទាំងអស់គ្នា ពិតជាមានមោទកភាពយ៉ាងក្រៃលែងចំពោះស្នាដៃដ៏ធំធេងជាប្រវត្តិសាស្ត្រមិនអាចកាត់ថ្លៃបានក្នុងការដឹកនាំប្រទេសកម្ពុជាទទួលបានជោគជ័យ និងភាពសម្បូររុងរឿងរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងសូមយកឱកាសដ៏វិសេសវិសាលនេះ ប្រកាសគាំទ្រឥតងាករេ ចំពោះបេក្ខភាពរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ធ្វើជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាគ្រប់ៗអាណត្តិជារៀងរហូត។

ជាថ្មីម្តងទៀត យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោះព្រំប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខជូនដល់ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រាបុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបតែសុខ និងចម្រើន ព្រមទាំងពុទ្ធពរជ័យប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២១

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**